E316

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 09 / 2014
ម៉ោង (Time/Heure) : 13:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

## ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Marie GUIRAUD

**<u>ជនជាប់ចោទ</u>**

នួន ជា
ខៀវ សំផន

**<u>មេធាវីជនជាប់ចោទ</u>**

សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២-១៩-០៩-២០០៧/អ.វ.ត.ក/អជសង អនុលោមតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលអង្គបុរេជំនុំជម្រះបានចេញនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១[1]។

**ក្រោយពី** សវនាការបឋមបន្ថែមក្នុងសំណុំរឿង ០០២ ដែលបានធ្វើកាលពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ និងដោយពិចារណាទៅលើសំណើផ្សេងៗដែលភាគីបានលើកឡើងនៅក្នុងសវនាការនោះ។

**បន្ទាប់ពីបានពិចារណានៅលើ** សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកាត់បន្ថយពេលសវនាការពិនិត្យភស្តុតាងក្នុងសំណុំរឿង ០០២/០២ មកត្រឹម ២ ឬ ៣ ថ្ងៃ ក្នុងមួយសប្តាហ៍ ដើម្បីឱ្យភាគីមានពេលរៀបចំបណ្តឹងសាទុក្ខ និង សារណាតបនានាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១[2]។

**បន្ទាប់ពីបានពិចារណានៅលើ** សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យកាត់បន្ថយចំនួនថ្ងៃសវនាការប្រចាំសប្តាហ៍នៅក្នុងអំឡុងពេលដែលកំពុងរៀបចំបញ្ចប់បណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១[3]។

**បន្ទាប់ពីបានពិចារណានៅលើ** សំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា សុំឱ្យសវនាការលើសំណុំរឿង ០០២/០២ ចាប់ផ្តើមនៅម៉ោង ៧:៣០ នាទីព្រឹក ហើយសុំឱ្យសវនាការប្រព្រឹត្តទៅតែពេលព្រឹកប៉ុណ្ណោះ ព្រោះថា នួន ជា អាចផ្តង់អារម្មណ៍បានល្អតែនៅពេលព្រឹក[4]។

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/1/26, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/2/12, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/4/14 និងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តចិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/5/9។

[2] ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ ទំព័រ ៣៧ (ភាសាអង់គ្លេស)។

[3] ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ ទំព័រ ៣៨ (ភាសាអង់គ្លេស)។

[4] ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ ទំព័រ ៣៨ (ភាសាអង់គ្លេស)។

**បន្ទាប់ពីបានពិចារណានៅលើ** សំណើរបស់ ខៀវ សំផន សុំឱ្យពន្យារពេលចាប់ផ្ដើមសវនាការលើសំណុំរឿង ០០២/០២ រហូតដល់ពេលអង្គជំនុំជម្រះតុលាការកំពូលចេញសាលដីកាស្ដាពរលើសំណុំរឿង ០០២/០១ ឬជាជម្រើសមួយទៀត សុំប្ដឹងជំទាស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង[5]។

**រម្លឹកឡើងវិញអំពី** សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ដែលបដិសេធសំណើរបស់ ខៀវ សំផន សុំពន្យារពេលចាប់ផ្ដើមសវនាការសំណុំរឿង ០០២/០២ និងអំពីការបញ្ជូនសំណើសុំប្ដឹងជំទាស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង សម្រាប់ជាជម្រើសមួយទៀតទៅក្រុមប្រឹក្សាពិសេសមួយដែលត្រូវបានចាត់តាំងឡើងដោយគណៈកម្មាធិការរដ្ឋបាលតុលាការ[6]។

**រម្លឹកបន្ថែមទៀតអំពី** វិធាន ៣៤(៥) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតមានការបន្តការចូលរួមសវនាការរបស់ចៅក្រមមួយ ឬច្រើនរូប ដែលរង់ចាំសេចក្ដីសម្រេចទៅលើបណ្ដឹងជំទាស់គាត់។

**កត់សម្គាល់ឃើញថា** ភាគីត្រូវបានអនុញ្ញាតឱ្យមានពេលវេលាបន្ថែមទៀត ដើម្បីដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ដែលនឹងត្រូវដាក់ទៅអង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ហើយមិនទាន់មានសេចក្ដីសម្រេចទៅលើសំណើរបស់ភាគីសុំពន្យាពេលវេលាកំណត់សម្រាប់ការដាក់សារណានៃបណ្ដឹងសាទុក្ខទាំងនេះនៅឡើយ[7]។

**បន្ទាប់ពីបានពិចារណានៅលើ** តម្រូវការធនធានជាច្រើនរបស់ភាគីនាពេលបច្ចុប្បន្នដើម្បីរៀបចំសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និងសារណានៃបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១។

---

[5] ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ ទំព័រ ៣៩ (ភាសាអង់គ្លេស)។ សំណើរបស់លោក ខៀវ សំផន សុំឱ្យ ពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្ដើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ឯកសារ E314/1 ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤។

[6] សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន ស្នើសុំពន្យារពេលក្នុងការចាប់ផ្ដើមសំណុំរឿង ០០២/០២ ឬជាជម្រើសមួយទៀត សុំដកសិទ្ធិពីចៅក្រមមិនឱ្យជំនុំជម្រះសំណុំរឿង ០០២ បន្តទៀត ឯកសារ E314/5 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤។

[7] សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និងសារណានៃបណ្ដឹងសាទុក្ខ ឯកសារ F3/3 ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤។

**ដោយយល់ឃើញថា** យ៉ាងហោចណាស់ក៏រហូតដល់ដំណាច់ខែ ធ្នូ ឆ្នាំ ២០១៤ នេះដែរ ភាគីនឹងទទួលបានប្រយោជន៍ពីការចាប់ផ្ដើមសវនាការពិនិត្យភ័ស្ដុតាងបន្ទាប់ពីការដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខលើសំណុំរឿង ០០២/០១ និងចំនួនសវនាការតិចជាងមុន នៅពេលកំពុងរៀបចំសារណានៃបណ្ដឹងសាទុក្ខ ដែលបន្ទាប់ពីនោះ កាលវិភាគសវនាការអាចនឹងត្រូវពិនិត្យឡើងវិញសាជាថ្មីទៀត។

**ដោយរម្លឹកឡើងវិញអំពី** របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រសម្រាប់ នួន ជា ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ដែលថា នួន ជា "ទន់ខ្សោយ" ប៉ុន្តែមានសុខភាពល្អធម្មតា បើគិតតាមវ័យ និងស្ថានភាពជំងឺប្រចាំកាយរបស់គាត់ ហើយលើកឡើងថា គាត់មានលទ្ធភាពអាច "ចូលរួមសវនាការដែលមានរយៈពេលពេញលេញ និងពេលវេលាសម្រាកជាធម្មតាទៅតាមកាលវិភាគរបស់តុលាការ"[8]។

**ដោយរម្លឹកបន្ថែមទៀតអំពី** របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រសម្រាប់ ខៀវ សំផន ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ដែលថា គាត់មានសុខភាពល្អធម្មតា បើទោះជាគាត់មានបញ្ហាសុខភាពខ្លះៗក្ដី ហើយលើកឡើងថា គាត់មានលទ្ធភាពអាច "ចូលរួមសវនាការដែលមានរយៈពេលពេញលេញ និងពេលវេលាសម្រាកជាធម្មតាទៅតាមកាលវិភាគរបស់តុលាការ"[9]។

**បន្ទាប់ពីបានពិចារណាឃើញថា** ក្រៅពីលទ្ធផលរកឃើញរបស់អ្នកជំនាញវេជ្ជសាស្ត្រ ជនជាប់ចោទអាចនឹងទទួលបានប្រយោជន៍ពីសវនាការដែលមានចំនួនតិចជាងមុនបន្តិច នៅក្នុងអំឡុងពេលនេះ។

**រម្លឹកឡើងវិញអំពី** សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីលំដាប់លំដោយនៃអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ និងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះក្នុងការកំណត់អាទិភាពទៅលើសវនាការពិនិត្យភ័ស្ដុតាងទៅលើសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់[10]។

---

[8] របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ នួន ជា ឯកសារ E301/10/6 ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤។ *សូមមើលផងដែរ* សេចក្ដីសម្រេចលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E301/11 ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ៧។

[9] របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ ខៀវ សំផន ឯកសារ E301/10/7 ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ៣៨។ *សូមមើលផងដែរ* សេចក្ដីសម្រេចលើសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ ឯកសារ E301/12 ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ៧។

[10] សេចក្ដីសម្រេចអំពីលំដាប់លំដោយនៃអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ ឯកសារ E315 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤។

**កត់សម្គាល់ថា** សេចក្តីសម្រេចដោយឡែកមួយនឹងត្រូវចេញពាក់ព័ន្ធនឹងលំដាប់លំដោយនៃសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវមកផ្តល់សក្ខីកម្មលើអង្គហេតុទាំងនេះ។

## ហេតុដូច្នេះ

**កំណត់កាលបរិច្ឆេទ** ចាប់ផ្តើមសវនាការពិនិត្យភ័ស្តុតាងវគ្គដំបូងក្នុងសំណុំរឿង ០០២/០២ ពី <u>ថ្ងៃ សុក្រ ទី ១៧ ខែ តុលា ឆ្នាំ ២០១៤ រហូតដល់ថ្ងៃ ព្រហស្បតិ៍ ទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤</u>។

**ប្រកាសថា** អង្គជំនុំជម្រះនឹងដំណើរការសវនាការ ៣ ថ្ងៃក្នុង ១ សប្តាហ៍ តាមកាលវិភាគសវនាការប្រចាំថ្ងៃដូចដែលធ្លាប់បានអនុវត្តនៅក្នុងសំណុំរឿង ០០២/០១ ដោយចាប់ផ្តើមសវនាការពីម៉ោង ៩:០០ នាទីព្រឹក និងបញ្ចប់នៅម៉ោង ៤:០០ នាទី រសៀល។ សវនាការនឹងផ្អាកសម្រាប់ការទទួលទានអាហារថ្ងៃត្រង់ពីម៉ោង ១២:០០ ថ្ងៃត្រង់ រហូតដល់ម៉ោង ១:៣០ រសៀល និងមានការសម្រាកម្តងនៅពេលព្រឹក និងម្តងទៀតនៅពេលរសៀល តាមការណែនាំរបស់ប្រធានអង្គជំនុំជម្រះ។

**ប្រកាសថា** ដោយសារតែចាប់ពីថ្ងៃទី ០៥ ដល់ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ជាថ្ងៃឈប់សម្រាកបុណ្យជាតិ និងដើម្បីឲ្យភាគីមានពេលវេលាសមស្របបន្ថែមទៀតសម្រាប់រៀបចំសារណានៃបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះនឹងមិនធ្វើសវនាការនៅចន្លោះថ្ងៃទី ៣១ ខែ តុលា រហូតដល់ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

**ជូនដំណឹង** ដល់ភាគីនានាថា ដោយអនុលោមតាមវិធាន ៨៩ *ស្ទួន* នៃវិធានផ្ទៃក្នុង សវនាការថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញានឹងត្រូវបានផ្តល់ឱកាសសម្រាប់ធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបអំពីការចោទប្រកាន់ចំពោះជនជាប់ចោទ ហើយជនជាប់ចោទ ឬ មេធាវីរបស់ជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន។

**ជូនដំណឹងបន្ថែមទៀត** ដល់ភាគីនានាថា ការស្តាប់សក្ខីកម្មដំបូងរបស់សាក្សីនឹងធ្វើឡើងនៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤។

**ភ្ជាប់ជាមួយដីកានេះ** នូវកាលវិភាគសវនាការពិនិត្យភស្តុតាងក្នុងសំណុំរឿង ០០២/០២ សម្រាប់អំឡុងពេលនេះរហូតដល់បំណាច់ឆ្នាំ ២០១៤។

ភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C.

**និល ណុន**